អន្តរប្ញទ្ធិ
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ៖ រាជរដ្ឋាភិបាលខ្មែរគួរធ្វើច្បាប់កម្រិតឲ្យអ្នកធ្វើវិនិយោគទុនបរទេសនៅកម្ពុជាយកកម្មករខ្មែរធ្វើការឲ្យបាន៨០% ។

Website: www.hoksavann.org

ថ្ងៃទី២០ ឧសភា ២០១០



ពលរដ្ឋខ្មែរនៅមានភាពក្រីក្រ រកការងារធ្វើមិនបាន មានពលរដ្ឋខ្មែរខ្លះបានត្រូវមេខ្យល់ដឹកនាំឲ្យទៅធ្វើការនៅបរទេសមានប្រទេសថៃជាដើម ត្រូវទទួលទុក្ខវេទនា មានខ្មែរខ្លះត្រូវទាហានថៃបាញ់សម្លាប់ផង ។ នៅពេលដែលខ្មែរបើកផ្សារសេរី មានអ្នកវិនិយោគទុនជាច្រើនបានមករកស៊ីនៅប្រទេសកម្ពុជា អ្នកវិនិយោគទុនជាច្រើនបានយកកម្មករខ្មែរឲ្យធ្វើការ ផ្ទុយទៅវិញអ្នកវិនិយោគទុនវៀតណាមដែលរដ្ឋាភិបាលខ្មែរបានផ្តល់ដីសម្បទានរាប់ម៉ឺនរាប់សែនហិកតាដើម្បីដាំដំណាំមានដាំកៅស៊ូជាដើម គ្មានឃើញយកកម្មករខ្មែរឲ្យធ្វើការច្រើនឡើយ គេយកតែជនជាតិវៀតណាមជាពិសេសយកទាហានវៀតណាមដែលចូលនិវត្តន៍ ។ ដើម្បីឲ្យទៅជាច្បាប់ គួររាជរដ្ឋាភិបាលខ្មែរធ្វើច្បាប់កម្រិតឲ្យគ្រប់អ្នកធ្វើវិនិយោគទុនបរទេស ដែលរកស៊ីនៅប្រទេសកម្ពុជា ត្រូវតែយកកម្មករខ្មែរឲ្យធ្វើការយ៉ាងហោចណាស់ឲ្យបាន៨០% ។

ចំពោះការធ្វើសម្បទានដីនេះ តាមរបាយការណ៍របស់អង្គការសហប្រជាជាតិបានរិះគន់ថា គេមិនដែលធ្វើសម្បទានដីរហូតដល់រាប់ម៉ឺនរាប់សែនហិកតា ហើយមានរយៈពេលរហូតដល់៩៩ឆ្នាំ ដូចរដ្ឋាភិបាលខ្មែរបានធ្វើដូចសព្វថ្ងៃនេះឡើយ ។ គេមានធ្វើចំពោះក្រុមហ៊ុនមួយតែមួយពាន់ឬពីរពាន់ហិកតា ហើយក្នុងរយៈពេលតែ២០ឆ្នាំឬ៣០ឆ្នាំប៉ុណ្ណោះ ។ ចំពោះការធ្វើសម្បទានដីនេះ បានធ្វើឲ្យពលរដ្ឋខ្មែរក្រីក្រកាន់តែខ្លាំងឡើង ។ ពលរដ្ឋខ្មែរដែលធ្លាប់តែម្ចាស់ដី មានចំណូលគ្រាន់បើ ឥឡូវនេះក្លាយជាកម្មករស៊ីឈ្នួលឲ្យនាយទុនអ្នកវិនិយោគទុន បានតំរៃយ៉ាងតិចតួចបំផុត ។ គម្លាតខុសគ្នារវាងអ្នកមាននិងក្រកើតមានកាន់តែខ្លាំងឡើងនៅប្រទេសកម្ពុជា មូលហេតុមកពីភោគផលកើតមាននៅប្រទេសកម្ពុជា បែងចែកគ្មានតម្លាភាពគ្មានយុត្តិធម៌ ។ រាជរដ្ឋាភិបាលខ្មែរឃុបឃិតជាមួយអ្នកធ្វើវិនិយោគទុន មិនបានបង់ពន្ធជូនរដ្ឋឲ្យបានពេញលេញឡើយ ។ លើសពីនេះទៅទៀត អ្នកកាន់អំណាចខ្មែរបានដេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានរបស់ខ្លួន ដោយមិនបានចរចាជាមួយប្រជាពលរដ្ឋឲ្យសុខចិត្ត មុននឹងយកដីគាត់ធ្វើសម្បទាន ។ មិនត្រឹមតែរុះរើផ្ទះប្រជាពលរដ្ឋប៉ុណ្ណោះទេ មានកន្លែងខ្លះដេញបាញ់ប្រជាពលរដ្ឋ ធ្វើឲ្យរបួសនិងស្លាប់ ហើយមានប្រជាពលរដ្ឋខ្លះបានត្រូវគេចាប់ដាក់គុកថែមទៀត ។

ប្រជាពលរដ្ឋអត់ការធ្វើ ជាពិសេសយុវជនយុវនារីជាសិស្សនិងនិស្សិតបានប្រឡងជាប់ចេញពីសាលាជាច្រើនពាន់ច្រើនម៉ឺននាក់ក្នុងមួយឆ្នាំៗ អត់ការធ្វើ រដ្ឋពុំបានដោះស្រាយឲ្យបានសំរេចជាវិជ្ជមានឡើយ ។ ពុំមានផែនការច្បាស់លាស់បង្កើតការងារឲ្យប្រជាពលរដ្ឋធ្វើឡើយ ។ ឧទាហរណ៍ទាហានខ្មែររាប់ម៉ឺននាក់ដែលរំសាយពីកងទ័ពគ្មានការងារធ្វើ ផ្ទុយទៅវិញទាហានវៀតណាមដែលចូលនិវត្តនិងរំលាយពីកងទ័ពដូចខ្មែរដែរ មកធ្វើការនៅប្រទេសកម្ពុជា ក្រោមរូបភាពវិនិយោគទុនដាំចំការកៅស៊ូ ។ អស្ចារ្យដែរ ខ្មែរមានដីប៉ុន្តែមិនចេះប្រើរកការងារឲ្យប្រជាពលរដ្ឋធ្វើ ចាញ់បរទេសរកការឲ្យប្រជាពលរដ្ឋរបស់គេធ្វើនៅលើដីរបស់ខ្មែរ និងមានផែនការវាតយកទឹកដីខ្មែរថែមទៀត ។

មូលហេតុដែលនាំឲ្យប្រជាពលរដ្ឋខ្មែរធ្វើចំណាកស្រុកចេញពីមាតុប្រទេសរបស់ខ្លួនទៅរកស៊ីនៅបរទេសមកពីភាពក្រីក្រ ដែលកាលពីសម័យដើមខ្មែរមិនដែលចាកចេញពីស្រុកទៅរកការងារធ្វើយ៉ាងដូច្នេះឡើយ បើគេជេរថាអាចោលស្រុកខឹងនឹងគេខ្លាំងណាស់ ។ ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋខ្មែរនេះ មានគ្រោះថ្នាក់ណាស់ ព្រោះមានមេខ្យល់បោកប្រាស ដូចបុរសខ្មែរ៨នាក់បានត្រូវជាប់គុកនៅប្រទេសឥណ្ឌា ដោយមេខ្យល់ខ្មែរនិងថៃ បោកយកទៅលក់ឲ្យបំរើកប៉ាល់នេសាទ ដោយស្ថិតនៅលើកប៉ាល់នេសាទជាយូរឆ្នាំ បង្ខំឲ្យធ្វើការយ៉ាងធ្ងន់ អាហារមិនគ្រប់គ្រាន់ បើមានជម្ងឺធ្ងន់ប្រើការមិនកើត គេច្រានទម្លាក់ឲ្យស្លាប់ក្នុងសមុទ្រតែម្តង ។ ដោយឃើញសភាពការណ៍ដ៏សាហាវដូច្នេះ មានខ្មែរមួយក្រុមទៀតដែលគេបោកឲ្យបំរើលើកប៉ាល់នេសាទដែរ បានលួចហែលទៅប្រទេសឥណ្ឌូណេស៊ី ។ ចំពោះស្ត្រីខ្មែរវិញ នៅពេលភៀសខ្លួនទៅប្រទេសថៃ ត្រូវថៃប្លន់រំលោភផ្លូវភេទ ក៏ដូចជាពេលនេះស្រុកសាន្តត្រាណទៅរកការធ្វើក៏ត្រូវថៃធ្វើបាបដូចគ្នា ។ ស្ត្រីខ្មែរទៅបំរើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ក៏ត្រូវរំលោភផ្លូវភេទ ធ្វើការគ្មានពេលសំរាក ត្រូវវាយដំពីម្ចាស់ផ្ទះ មានស្ត្រីខ្មែរខ្លះត្រូវគេលក់បន្តគ្នាឲ្យធ្វើជាស្រីពេស្យា មានស្ត្រីខ្មែរខ្លះត្រូវអង្គការក្រៅរដ្ឋាភិបាលរំដោះបានពីបនស្រីពេស្យាត្រឡប់មកប្រទេសកម្ពុជាវិញ ទៅជាឆ្កួតឡប់សតិ ដោយពេលគេឲ្យទៅធ្វើជាស្រីពេស្យានោះត្រូវបង្ខំឲ្យប្រើគ្រឿងញៀន ។ នៅឯចិនតៃវ៉ាន់វិញ ស្ត្រីខ្មែរជាង៥ពាន់នាក់ (៥,០០០នាក់) ត្រូវទៅដល់ប្រទេសចិនតៃវ៉ាន់ដោយខុសច្បាប់ តាមរូបភាពរៀបការក្លែងក្លាយ ដោយរៀបចំឡើងដោយមេខ្យល់ជាឈ្មួញកណ្តាលជាតិខ្មែរនិងចិនតៃវ៉ាន់ ។ ប្រុសចិនតៃវ៉ាន់ដែលបានរៀបការជាមួយស្រីអាស៊ីមានខ្មែរជាដើមនោះ ជាប្រុសអស់សាច់ខ្ចិលច្រអូសមានខ្លះមិនចេះអក្សរផង ជាប្រុសចាស់ពិការ ដែលស្ត្រីចិនតៃវ៉ាន់មិនត្រូវការយកមកធ្វើជាប្តីឡើយ ។ ស្ត្រីខ្មែរមានចំនួនតិចណាស់ដែលប្រុសតៃវ៉ាន់យកធ្វើជាប្រពន្ធពេញលក្ខណៈ ក្រៅពីនេះភាគច្រើនបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ក្នុងរោងចក្រ ប្រាក់ខែតិច ហើយស្ត្រីខ្មែរមួយភាគបានត្រូវបង្ខំឲ្យធ្វើជាស្រីពេស្យា ។ល។

ភាពរងទុក្ខវេទនារបស់ខ្មែរធ្វើចំណាកស្រុកទាំងប្រុសទាំងស្រីទៅរកការធ្វើនៅបរទេសនេះ កើតមកពីភាពក្រីក្រគ្មានការងារធ្វើនៅប្រទេសរបស់ខ្លួន ប្រាក់ខែថោក ។ នេះជាភារកិច្ចរបស់រាជរដ្ឋាភិបាលត្រូវបង្កើតការងារឲ្យប្រជាពលរដ្ឋធ្វើ ដើម្បីបន្ថយការធ្វើចំណាកស្រុក និងដើម្បីរក្សាកិត្តិយសប្រទេសកម្ពុជា ។ ដើម្បីឲ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលខ្លួនឯងត្រូវបំបាត់អំពើពុករលួយ ឃុបឃិតជាមួយអ្នកវិនិយោគទុន ធ្វើបាបពលរដ្ឋរបស់ខ្លួន ។៚